ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ក្នុងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅ ស្តីពី
# "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច"

នៅសណ្ឋាគារ Raffles Le Royal

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**សូមគោរព៖**

- **ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ជាទីគោរព**
- **លោក TANINAI Ichitomo អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា**
- **លោក Kazumasa Sanui ប្រធានតំណាង JICA ប្រចាំកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច" ដែលទើបតែត្រូវបានបោះផ្សាយដោយរោងពុម្ពអន្តរជាតិ Rouledge នៃចក្រភពអង់គ្លេស កាលពីខែកញ្ញាកន្លងទៅនេះ។ ខ្ញុំសូមស្វាគមន៍និងថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងពិធីនាពេលនេះ ទាំងការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ លើបណ្តាញសង្គមរបស់ធនាគារជាតិនៃកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សៀវភៅនេះ គឺជាលទ្ធផលនៃកិច្ចសហការស្រាវជ្រាវរួមគ្នារវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ចាប់តាំងពីឆ្នាំ២០១៣ មកម្ល៉េះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ JICA ដែលបានរួមចំណែកក្នុងការស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះលោកសាស្ត្រាចារ្យ Hidenobu Okuda ដែលបានសហការរៀបចំ ដឹកនាំ និងកែសម្រួលខ្លឹមសារនៃអត្ថបទស្រាវជ្រាវ និងអ្នកនិពន្ធគ្រប់រូបដែលបានរួមចំណែកស្រាវជ្រាវលើផ្នែកនីមួយៗ ដែលបានធ្វើឱ្យសៀវភៅនេះ ក្លាយជាមូលដ្ឋានមួយសម្រាប់ការស្រាវជ្រាវថ្មីៗបន្ថែមទៀត កាន់តែស៊ីជម្រៅ និងជាធាតុចូលយ៉ាងសំខាន់ក្នុងការរៀបចំតាក់តែងគោលនយោបាយនានាដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដូចដែលលោក Kazumasa Sanui បានលើកឡើង។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ដុល្លារូបនីយកម្មបានកើតឡើងក្នុងស្ថានភាពដែលជំនឿទុកចិត្តលើប្រាក់រៀលមានភាពទន់ខ្សោយ ក្រោយពីសង្គ្រាមស៊ីវិលជិតពីរទសវត្សរ៍ និងការហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នៃប្រាក់ដុល្លារអាមេរិក ក្នុងពេលរៀបចំការបោះឆ្នោតសកលលើកដំបូងនៅកម្ពុជា ដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា ដែលហៅកាត់ថា UNTAC។ ជាការពិត ដុល្លារូបនីយកម្មបានរួមចំណែកជួយស្តារសេដ្ឋកិច្ច និងអមដំណើរនៃការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ ទោះយ៉ាងណា ដុល្លារូបនីយកម្មខ្ពស់ បានដាក់កំហិតលើការអនុវត្តគោលនយោបាយរូបិយវត្ថុ។ នៅពេលដែលទំហំសេដ្ឋកិច្ចកម្ពុជាកើនឡើងកាន់តែធំ ការខ្វះលទ្ធភាពប្រើប្រាស់គោលនយោបាយរូបិយវត្ថុដោយពេញលេញ ក៏ធ្វើឱ្យសេដ្ឋកិច្ចកាន់តែងាយរងគ្រោះផងដែរ ហើយដែលបណ្តាលឱ្យពឹងផ្អែកតែទៅលើគោលនយោបាយសារពើពន្ធ។ បច្ចុប្បន្ន ស្ទើរតែគ្រប់ប្រទេសទាំងអស់ លំហគោលនយោបាយសារពើពន្ធបានរួមតូចទៅៗ ដោយសារតែវិបត្តិផ្សេងៗ ហើយប្រទេសនានាលើពិភពលោក បានពឹងផ្អែកកាន់តែច្រើនលើគោលនយោបាយរូបិយវត្ថុ ដើម្បីស្តារកំណើនសេដ្ឋកិច្ច។ ជាក់ស្តែង នៅក្នុងពេលវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៧-២០០៨ ធនាគារកណ្តាលជាច្រើនបានកាត់បន្ថយអត្រា

ការប្រាក់គោលរហូតដល់ស្ទើរស្មើសូន្យ ដើម្បីជំរុញការវិនិយោគនិងការប្រើប្រាស់ ហើយក្នុងអំឡុងវិបត្តិកូវីដ-១៩ ធនាគារកណ្តាលថែមទាំងបញ្ចេញសាច់ប្រាក់ដើម្បីជួយសេដ្ឋកិច្ចទៀតផង ដែលការអនុវត្តនេះត្រូវបានគេហៅថាគោលនយោបាយរូបិយវត្ថុវិសាមញ្ញ (Unconventional Monetary Policies)។ ចំណែកឯ នៅក្រោយវិបត្តិកូវីដ-១៩ ធនាគារកណ្តាលភាគច្រើនបានបង្កើនអត្រាការប្រាក់គោលមកវិញ ដើម្បីប្រឆាំងនឹងការកើនឡើងនៃអតិផរណា។ លទ្ធភាពក្នុងការបង្កើនឬបន្ថយអត្រាការប្រាក់គោល ឬចាក់បញ្ចូលសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ចបានប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការប្រើប្រាស់ពេញលេញ និងទូលំទូលាយនៃរូបិយវត្ថុជាតិ។

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសស្ថិរភាពនយោបាយ បានផ្តល់ភាពអំណោយផលដល់ការពង្រឹងការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ខណៈដែលសមាមាត្រនៃការប្រើប្រាស់ដុល្លារអាមេរិកនៅតែមានកម្រិតខ្ពស់។ បញ្ហានេះស្របទៅនឹងការរកឃើញនានារបស់អ្នកស្រាវជ្រាវ ដែលថាពេលដែលដុល្លារូបនីយកម្មកើនដល់ចំណុចខ្ពស់មួយហើយ នឹងមិនងាយថយចុះវិញបានទេ (Hysterisis of Dollarization) គឺតម្រូវឱ្យមានការអនុវត្តគោលនយោបាយលើកទឹកចិត្តផងនិងគាំទ្រផងដើម្បីកាត់បន្ថយកម្រិតដុល្លារូបនីយកម្ម។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា បានពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលជាប្រចាំ និងបានអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផ្អែកលើយន្តការទីផ្សារ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក។ កត្តាទាំងនេះបានបង្កើនបរិមាណប្រាក់រៀលក្នុងចរាចរណ៍ពី ០,៨៥ទ្រីលានរៀលកាលពី២០ឆ្នាំមុនដល់១៤,៥ទ្រីលានរៀលនាពេលបច្ចុប្បន្ន ពោលគឺកើនឡើងប្រមាណ ១៦ ដង ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច។ កំណើននេះជាជំហាននិងជាក្តីសង្ឃឹមដ៏សំខាន់ ដើម្បីឈានទៅបង្កើនការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។

ខ្ញុំសូមគូសបញ្ជាក់ថា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលមិនមែនជាការងារឬការទទួលខុសត្រូវផ្តាច់មុខ របស់ក្រសួង-ស្ថាប័ន ឬវិស័យណាមួយឡើយ តែគឺជាការងាររួមរបស់គ្រប់ក្រសួង-ស្ថាប័ន វិស័យឯកជន និងប្រជាជនទូទៅទាំងអស់គ្នា

ដែលទាមទារ ការសហការនិងគាំទ្របន្ថែមទៀត ឱ្យកាន់តែសកម្មនិងមានសង្គតិភាព។ ក្នុងន័យនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះ ការចូលរួមចំណែកពីគ្រប់ភាគីទាំងអស់ លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ជាក់ស្តែង មានក្រុមហ៊ុន-សហគ្រាសកាន់តែច្រើន បានបើកប្រាក់បៀវត្សរ៍ដល់បុគ្គលិក-និយោជិតជាប្រាក់រៀល នៅតាមទីផ្សារទំនើបនានាក៏បាន បិទស្លាកថ្លៃជារៀល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនក៏បានខិតខំបង្កើនឥណទាន និងប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀល។ ទាំងនេះគឺជាវឌ្ឍនភាពមួយដ៏សំខាន់ សម្រាប់ការ អនុវត្តវិធានការបន្តបន្ទាប់ទៀតដោយពិលាស។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ខ្ញុំសូមចូលរួមអបអរសាទរចំពោះការបោះផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា" របស់យើងនាពេលនេះ។ ខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវនេះ នឹងផ្តល់បទពិសោធន៍ដ៏មានតម្លៃផងដែរដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា ក្នុងការគ្រប់គ្រងបញ្ហាដុល្លារូបនីយកម្ម និងការប្រើប្រាស់គោលនយោបាយ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ឱ្យបានកាន់តែប្រសើរ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយផងដែរ ដែលការសម្ពោធសៀវភៅនេះធ្វើឡើងក្នុងឱកាសនៃខួប ៧០ឆ្នាំនៃចំណងការទូតមិត្តភាពកម្ពុជា-ជប៉ុន ដែលបង្ហាញកាន់តែច្បាស់ពីមិត្តភាពដ៏រឹងមាំនិងយូរអង្វែងរបស់កម្ពុជា-ជប៉ុន ព្រមទាំងការចូលរួមចំណែករបស់ប្រទេសជប៉ុន ក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទីភ្នាក់ងារ JICA អ្នកស្រាវជ្រាវ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលចូលរួមផ្តល់កិច្ចសហការ ក៏ដូចជាការគាំទ្រ ដើម្បីឱ្យការស្រាវជ្រាវ និងរៀបចំតាក់តែងសៀវភៅរបស់យើងអាចបញ្ចប់ទៅបានប្រកបដោយជោគជ័យ និងមានគុណតម្លៃខ្ពស់ក្នុងមជ្ឈដ្ឋានស្រាវជ្រាវ។

**សូមអរគុណ**